| ឯកសារតម្រូវការផ្ទេរអចលនវត្ថុនាំចមូល | | |
|---|---|---|
| ល.រ | ឯកសារតម្រូវ | ចំនួន (ច្បាប់) |
| **I.** | **ការផ្ទេរតាមរយៈកិច្ចសន្យា (លក់ទិញ ឬប្រទានកម្ម ឬដូរ)** | |
| 1 | ពាក្យសុំចុះបញ្ជី (ច្បាប់ដើម) | 02 |
| 2 | កិច្ចសន្យាលក់ទិញ ឬប្រទានកម្ម ឬដូរដោយលិខិតយថាភូត ។ បើពុំមានកិច្ចសន្យាលក់ទិញ ឬប្រទានកម្ម ឬដូរ ដោយលិខិតយថាភូតទេ គូភាគី ត្រូវមានសាក្សី ០២នាក់ អមមកជាមួយ ហើយអាចស្នើសុំឱ្យមន្ត្រីសុរិយោដី នៅការិយាល័យ ដនសភ. ក្រុង-ស្រុក-ខណ្ឌ ជួយរៀបចំដើម្បីធ្វើនីតិវិធីនៃការចុះបញ្ជីបាន(ច្បាប់ដើម) | 02 |
| 3 | កិច្ចសន្យាលក់ទិញដោយលិខិតយថាភូត ដែលមានការសន្យាពិសេសនៃការលោះ ក្នុងករណីពាក្យសុំចុះបញ្ជីអំពីការសន្យាពិសេសនៃការលោះ ត្រូវបានធ្វើឡើងព្រមគ្នាជាមួយពាក្យសុំចុះបញ្ជីអំពីការផ្ទេរ (ច្បាប់ដើម ០២ច្បាប់ និងច្បាប់ចម្លងដែលបានធ្វើនីត្យានុកូលកម្ម ០១ច្បាប់) | 03 |
| 4 | កិច្ចសន្យាហាមមិនឱ្យបែងចែកអចលនវត្ថុអវិភាគ ក្នុងករណីទ្រព្យអវិភាគ ហើយពាក្យសុំចុះបញ្ជីអំពីកិច្ចសន្យាហាមមិនឱ្យបែងចែកអចលនវត្ថុអវិភាគ ត្រូវបានធ្វើឡើងព្រមគ្នាជាមួយពាក្យសុំចុះបញ្ជីផ្ទេរ(ច្បាប់ដើម ០១ច្បាប់ និងច្បាប់ចម្លងដែលបានធ្វើនីត្យានុកូលកម្ម ០២ ច្បាប់) | 03 |
| 5 | ឯកសារបញ្ជាក់ការទទួលបានការអនុញ្ញាតពីតុលាការ ក្នុងករណីអចលនវត្ថុ ដែលជាកម្មវត្ថុនៃការលក់ទិញ ឬប្រទានកម្ម ឬដូរ ជារបស់អនីតិជនស្ថិតក្រោមអាណាព្យាបាល ឬជនស្ថិតក្រោមអាណាព្យាបាលទូទៅ ហើយកំពុងត្រូវបានប្រើប្រាស់ជាលំនៅដ្ឋានរបស់ជននោះ (ច្បាប់ដើម ឬច្បាប់ចម្លងដែលបានធ្វើនីត្យានុកូលកម្ម) | 03 |
| 6 | ឯកសារបញ្ជាក់អត្តសញ្ញាណ ចំនួន ០៣ច្បាប់ របស់បុគ្គលដាក់ពាក្យសុំចុះបញ្ជី ៖ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬសេចក្ដីចម្លងសំបុត្រកំណើត ឬសេចក្ដីចម្លងសំបុត្របញ្ជាក់កំណើត ឬលិខិត ឆ្លងដែន ឬអត្តសញ្ញាណប័ណ្ណមន្ត្រីរាជការ (បើជារូបវន្តបុគ្គល) លក្ខន្តិកៈ និងឯកសារបញ្ជាក់ការចុះបញ្ជីនីតិបុគ្គល (បើជានីតិបុគ្គល) ឬឯកសារផ្សេងទៀត (ច្បាប់ចម្លងដែលបានធ្វើនីត្យានុកូលកម្មលើកលែងតែសេចក្ដីចម្លងសំបុត្រកំណើត ឬសេចក្ដីចម្លងសំបុត្របញ្ជាក់កំណើត ដែលត្រូវយកច្បាប់ដើម) | 03 |
| 7 | ឯកសារបញ្ជាក់ប្រភេទទ្រព្យសម្បត្តិរបស់បុគ្គលមានសិទ្ធិចុះបញ្ជី ដែលជារូបវន្តបុគ្គល ៖ | 03 |

| | | |
|---|---|---|
| | -បើជាទ្រព្យរួមប្តី ប្រពន្ធ ត្រូវមានជាអាទិ៍ ÷ សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ឬ សេចក្តីចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ កិច្ចសន្យាទ្រព្យសម្បត្តិ ប្តី ប្រពន្ធ (ប្រសិនបើមាន) ឯកសារបញ្ជាក់ការទទួលបានទ្រព្យក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ (លើកលែងតែទ្រព្យដែលសហព័ទ្ធ ទទួលបានដោយប្រទានកម្ម ឬសន្តតិកម្ម ឬ អច្ច័យទាន ឬទ្រព្យជាតម្លៃតបដែលទទួលបានពីការចាត់ចែកទ្រព្យដោយឡែក)<br>-បើជាទ្រព្យដោយឡែក ត្រូវមានជាអាទិ៍ ÷ ឯកសារបញ្ជាក់អំពីស្ថានភាពស៊ីវិល (សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ឬសេចក្តីចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ ឬ លិខិតបញ្ជាក់លីវ ឬមេម៉ាយ ឬពោះម៉ាយ ឬសេចក្តីសម្រេចរបស់តុលាការ អំពីអវត្តមាន ឬការបាត់ខ្លួនរបស់សហព័ទ្ធម្ខាងទៀត) កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ (ប្រសិនបើមាន) ឯកសារបញ្ជាក់ការទទួលបានទ្រព្យនៅមុនពេលរៀបអាពាហ៍ពិពាហ៍ ឬទទួលបានដោយ ប្រទានកម្ម ឬសន្តតិកម្ម ឬអច្ច័យទាន ក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ឬ ទទួលបានពីការចាត់ចែងទ្រព្យសម្បត្តិដោយឡែក ឬបន្ថែមការបញ្ជាក់របស់សហព័ទ្ធម្ខាងទៀត<br>-ឯកសារបញ្ជាក់អំពីចំណែករបស់ម្ចាស់សិទ្ធិម្នាក់ៗ ប្រសិនបើមាន (បើជាទ្រព្យកម្មសិទ្ធិអវិភាគ ឬទ្រព្យសហភោគី) ឯកសារបញ្ជាក់អំពីចំណែកឯកជន និងចំណែករួម (បើជាទ្រព្យសហកម្មសិទ្ធិ) (ច្បាប់ដើម ឬច្បាប់ចម្លងដែលបានធ្វើនីត្យានុកូលកម្ម) | |
| 8 | ឯកសារបញ្ជាក់សិទ្ធិតំណាងរបស់អភិបាល តំណាងឱ្យនីតិបុគ្គលក្នុងករណីអ្នកដាក់ពាក្យសុំចុះបញ្ជីជានីតិបុគ្គល (ច្បាប់ដើម ០១ច្បាប់ និងច្បាប់ចម្លងដែលបានធ្វើនីត្យានុកូលកម្ម ០២ច្បាប់) | 03 |
| 9 | ឯកសារបញ្ជាក់សិទ្ធិតំណាង ក្នុងករណីអ្នកដាក់ពាក្យសុំចុះបញ្ជីជាជនស្ថិតក្រោមអ្នកតំណាង ដែលកំណត់ដោយច្បាប់ (ច្បាប់ដើម ០១ច្បាប់ និងច្បាប់ចម្លងដែលបានធ្វើនីត្យា-នុកូលកម្ម ០២ច្បាប់) | 03 |
| 10 | ឯកសារប្រគល់សិទ្ធិតំណាង ក្នុងករណីពាក្យសុំចុះបញ្ជីធ្វើឡើងដោយអ្នកតំណាងដោយអាណត្តិ (ច្បាប់ដើម ០១ច្បាប់ និងច្បាប់ចម្លងដែលបានធ្វើនីត្យានុកូលកម្ម ០២ ច្បាប់) | 03 |
| 11 | ប័ណ្ណអចលនវត្ថុជាកម្មវត្ថុនៃការលក់ទិញ ឬប្រទានកម្ម ឬដូរ (ច្បាប់ដើម) | 01 |
| 12 | ឯកសារពាក់ព័ន្ធផ្សេងទៀត ក្នុងករណីចាំបាច់ ÷ ........................................<br>(ច្បាប់ដើម ឬច្បាប់ចម្លងដែលបានធ្វើនីត្យានុកូលកម្ម) | 03 |

| II. | **ការផ្ទេរតាមរយៈសន្តតិកម្ម (សន្តតិកម្មតាមច្បាប់ ឬសន្តតិកម្មតាមមតកសាសន៍)** | |
|---|---|---|
| 1 | ពាក្យសុំចុះបញ្ជី (ច្បាប់ដើម) | 02 |
| 2 | សេចក្តីចម្លងសំបុត្រមរណភាព ឬសេចក្តីចម្លងសំបុត្របញ្ជាក់មរណភាពរបស់មរតកជន (ច្បាប់ដើម) | 03 |
| 3 | មរតកសាសន៍ដោយលិខិតយថាភូត ក្នុងករណីសន្តតិកម្មតាមមរតកសាសន៍ដោយលិខិតយថាភូត(ច្បាប់ដើម ឬច្បាប់ចម្លងដែលបានធ្វើនីត្យានុកូលកម្ម) | 03 |
| 4 | មរតកសាសន៍ដែលតុលាការបានបញ្ជាក់ភាពត្រឹមត្រូវនៃមរតកសាសន៍នោះ ក្នុងករណីសន្តតិកម្ម តាមមរតកសាសន៍ ក្រៅពីលិខិតយថាភូត (ច្បាប់ដើម ឬច្បាប់ចម្លងដែលបានធ្វើនីត្យានុកូលកម្ម) | |
| 5 | ឯកសារបញ្ជាក់អំពីអភ័ព្វបុគ្គលនៃសន្តតិកម្ម (ប្រសិនបើមាន) ឯកសារបញ្ជាក់អំពីការកាត់ផ្តាច់មរតកពីសន្តតិជន (ប្រសិនបើមាន) ឯកសារបញ្ជាក់អំពីការផ្តាច់មរតកដោយមតកសាសន៍ (ប្រសិនបើមាន) ឯកសារបញ្ជាក់អំពីការលុបចោលនូវការផ្តាច់មរតកពីសន្តតិជន (ប្រសិនបើមាន) ឯកសារបញ្ជាក់អំពីការលុបចោលនូវមតកសាសន៍ (ប្រសិនបើមាន) ឯកសារបញ្ជាក់អំពីការលុបចោលដោយការបដិសេធលិខិតមរតកសាសន៍ (ប្រសិនបើមាន) ឯកសារបញ្ជាក់អំពីសន្តតិកម្មជំនួស (ប្រសិនបើមាន) (ច្បាប់ដើម ឬច្បាប់ចម្លងដែលបានធ្វើនីត្យានុកូលកម្ម) | 03 |
| 6 | ឯកសារបញ្ជាក់ជាសន្តតិជន ÷ សេចក្តីចម្លងសំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើតរបស់សន្តតិជន សំបុត្រតំណវង្សត្រកូល សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ឬសេចក្តីចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ បើជាសហព័ទ្ធរបស់មតកជន ឯកសារបញ្ជាក់សមត្ថភាពរបស់សន្តតិជនក្នុងការទទួលមរតក ដែលចេញដោយតុលាការ ឬឯកសារផ្សេងទៀត (ច្បាប់ដើម) | 03 |
| 7 | ឯកសារបញ្ជាក់ការយល់ព្រមដោយមានកម្រិត ឬការបោះបង់សន្តតិកម្ម ដែលទទួលបានការអនុញ្ញាត ពីតុលាការ ក្នុងករណីមានសន្តតិជនយល់ព្រមដោយមានកម្រិត ឬបោះបង់សន្តតិកម្ម (ច្បាប់ដើម ០១ច្បាប់ និងច្បាប់ចម្លងដែលបានធ្វើនីត្យានុកូលកម្ម ០២ច្បាប់) | 03 |
| 8 | ឯកសារបញ្ជាក់អំពីការបោះបង់អច្ច័យទានសាកល ដែលទទួលបានការអនុញ្ញាតពីតុលាការ ក្នុងករណីមានអច្ច័យលាភី បោះបង់អច្ច័យទានសាកល (ច្បាប់ដើម ០១ច្បាប់ និងច្បាប់ចម្លងដែលបានធ្វើនីត្យានុកូលកម្ម ០២ច្បាប់) | 03 |

| | | |
|---|---|---|
| 9 | ឯកសារបញ្ជាក់អំពីអ្នកប្រតិបត្តិមតកសាសន៍ ក្នុងករណីមានអ្នកប្រតិបត្តិមតកសាសន៍ (ច្បាប់ដើម ឬច្បាប់ចម្លងដែលបានធ្វើនីត្យានុកូលកម្ម) | 03 |
| 10 | ឯកសារបញ្ជាក់អំពីអំឡុងពេលដែលមតកជន ហាមឃាត់មិនឱ្យបែងចែកមរតក ក្នុងករណីមតកជនបានកំណត់អំឡុងពេលហាមមិនឱ្យបែងចែកមរតកតាមមតកសាសន៍ (ច្បាប់ដើម ឬច្បាប់ចម្លងដែលបានធ្វើនីត្យានុកូលកម្ម) | 03 |
| 11 | ឯកសារបញ្ជាក់ការព្រមព្រៀងរបស់សន្តតិជន ក្នុងការបែងចែកមរតក ដោយលិខិតយថាភូត (ការព្រមព្រៀងបែងចែកដីក្នុងចំណែកដោយព្រមព្រៀងជាអាទិ៍) ក្នុងករណីមានការព្រមព្រៀង បែងចែកមរតក (ច្បាប់ដើម ០១ច្បាប់ និងច្បាប់ចម្លងដែលបានធ្វើ នីត្យានុកូលកម្ម ០២ច្បាប់) | 03 |
| 12 | សេចក្តីសម្រេចរបស់តុលាការអំពីការបែងចែកមរតក (សាលក្រមឬសាលដីកាស្ថាពរ ឬកំណត់ហេតុ សះជា ជាអាទិ៍) ក្នុងករណីមិនមានការព្រមព្រៀងបែងចែកមរតក (ច្បាប់ដើម ឬច្បាប់ចម្លងដែលបានធ្វើនីត្យានុកូលកម្ម) | 03 |
| 13 | កិច្ចសន្យាហាមមិនឱ្យបែងចែកអចលនវត្ថុអវិភាគ ក្នុងករណីទ្រព្យអវិភាគ ហើយពាក្យសុំចុះបញ្ជីអំពីកិច្ចសន្យាហាមមិនឱ្យបែងចែកអចលនវត្ថុអវិភាគ ត្រូវបានធ្វើឡើងព្រមគ្នាជាមួយពាក្យសុំចុះបញ្ជីផ្ទេរ(ច្បាប់ដើម ០១ច្បាប់ និងច្បាប់ចម្លងដែលបានធ្វើនីត្យានុកូលកម្ម ០២ច្បាប់) | 03 |
| 14 | ឯកសារបញ្ជាក់អត្តសញ្ញាណរបស់បុគ្គលដាក់ពាក្យសុំចុះបញ្ជី ÷ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬ សេចក្តីចម្លងសំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើត ឬលិខិតឆ្លងដែន ឬ អត្តសញ្ញាណប័ណ្ណមន្ត្រីរាជការ (បើជារូបវន្តបុគ្គល) លក្ខន្តិកៈ និងឯកសារបញ្ជាក់ការចុះបញ្ជីនីតិបុគ្គល(បើជានីតិបុគ្គល) ឬឯកសារផ្សេងទៀត(ច្បាប់ចម្លងដែលបានធ្វើនីត្យានុកូលកម្ម លើកលែងតែសេចក្តីចម្លងសំបុត្រកំណើត ឬ សេចក្តីចម្លងសំបុត្របញ្ជាក់កំណើតដែលត្រូវយកច្បាប់ដើម) | 03 |
| 15 | ឯកសារបញ្ជាក់សិទ្ធិតំណាង ក្នុងករណីអ្នកដាក់ពាក្យសុំចុះបញ្ជីជាជនស្ថិតក្រោមអ្នកតំណាងដែលកំណត់ដោយច្បាប់ (ច្បាប់ដើម ០១ច្បាប់ និងច្បាប់ចម្លងដែលបានធ្វើនីត្យានុកូលកម្ម ០២ច្បាប់) | 03 |
| 16 | ឯកសារប្រគល់សិទ្ធិតំណាង ក្នុងករណីពាក្យសុំចុះបញ្ជី ធ្វើឡើងដោយអ្នកតំណាងដោយអាណត្តិ (ច្បាប់ដើម ០១ច្បាប់ និងច្បាប់ចម្លងដែលបានធ្វើនីត្យានុកូលកម្ម ០២ច្បាប់) | 03 |

| | | |
|---|---|---|
| 17 | ប័ណ្ណអចលនវត្ថុ ជាកម្មវត្ថុនៃសន្តតិកម្ម (ច្បាប់ដើម) | 01 |
| 18 | ឯកសារពាក់ព័ន្ធផ្សេងទៀត ក្នុងករណីចាំបាច់ ÷ ........................................... (ច្បាប់ដើម ឬច្បាប់ចម្លងដែលបានធ្វើនីត្យានុកូលកម្ម) | 03 |
| **III.** | **ការផ្ទេរតាមរយៈសេចក្តីសម្រេចរបស់តុលាការ ឬអាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀត** | |
| 1 | ពាក្យសុំចុះបញ្ជី (ច្បាប់ដើម) | 02 |
| 2 | សេចក្តីសម្រេចរបស់តុលាការ ដែលបានចូលជាស្ថាពរ (សាលក្រម/ សាលដីកា/ ដីកាសម្រេច/ កំណត់ហេតុ សះជា/ កំណត់ហេតុទទួលស្គាល់នូវការទាមទារ) ឬសេចក្តីសម្រេចរបស់អាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀត ដែលមានអានុភាពអនុវត្ត (ច្បាប់ដើម ឬច្បាប់ចម្លងដែលបានធ្វើនីត្យានុកូលកម្ម) | 03 |
| 3 | កំណត់ហេតុអនុវត្តសេចក្តីសម្រេចរបស់តុលាការ ឬអាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀត ប្រសិនបើមាន (ច្បាប់ដើម ឬច្បាប់ចម្លងដែលបានធ្វើនីត្យានុកូលកម្ម) | 03 |
| 4 | ឯកសារបញ្ជាក់ការព្រមព្រៀងបែងចែកទ្រព្យសម្បត្តិ ក្នុងករណីលែងលះ ប្រសិនបើមាន (ច្បាប់ដើម ឬច្បាប់ចម្លងដែលបានធ្វើនីត្យានុកូល) | 03 |
| 5 | កិច្ចសន្យាហាមមិនឱ្យបែងចែកអចលនវត្ថុអវិភាគ ក្នុងករណីទ្រព្យអវិភាគ ហើយពាក្យសុំចុះបញ្ជី អំពីកិច្ចសន្យាហាមមិនឱ្យបែងចែកអចលនវត្ថុអវិភាគ ត្រូវបានធ្វើឡើងព្រមគ្នាជាមួយពាក្យសុំចុះបញ្ជីផ្ទេរ(ច្បាប់ដើម ០១ច្បាប់ និងច្បាប់ចម្លងដែលបានធ្វើនីត្យានុកូលកម្ម ០២ច្បាប់) | 03 |
| 6 | ឯកសារបញ្ជាក់អត្តសញ្ញាណរបស់បុគ្គលដាក់ពាក្យសុំចុះបញ្ជី ÷ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬសេចក្តីចម្លងសំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើត ឬលិខិតឆ្លងដែន ឬអត្តសញ្ញាណប័ណ្ណមន្ត្រីរាជការ(បើជារូបវន្តបុគ្គល) លក្ខន្តិកៈ និងឯកសារបញ្ជាក់ការចុះបញ្ជីនីតិបុគ្គល (បើជានីតិបុគ្គល) ឬឯកសារផ្សេងទៀត (ច្បាប់ចម្លងដែលបានធ្វើនីត្យានុកូលកម្ម លើកលែងតែសេចក្តីចម្លងសំបុត្រកំណើត ឬ សេចក្តីចម្លងសំបុត្របញ្ជាក់កំណើតដែលត្រូវយកច្បាប់ដើម) | 03 |
| 7 | ឯកសារបញ្ជាក់សិទ្ធិតំណាងរបស់អភិបាល តំណាងឱ្យនីតិបុគ្គលក្នុងករណីអ្នកដាក់ពាក្យសុំចុះបញ្ជីជានីតិបុគ្គល (ច្បាប់ដើម ០១ច្បាប់ និងច្បាប់ចម្លងដែលបានធ្វើនីត្យានុកូលកម្ម ០២ច្បាប់) | 03 |

| | | |
|---|---|---|
| 8 | ឯកសារបញ្ជាក់សិទ្ធិតំណាង ក្នុងករណីអ្នកដាក់ពាក្យសុំចុះបញ្ជីជាជនស្ថិតក្រោមអ្នកតំណាងដែលកំណត់ដោយច្បាប់ (ច្បាប់ដើម ០១ច្បាប់ និងច្បាប់ចម្លងដែលបានធ្វើនីត្យានុកូលកម្ម ០២ច្បាប់) | 03 |
| 9 | ឯកសារប្រគល់សិទ្ធិតំណាង ក្នុងករណីពាក្យសុំចុះបញ្ជី ធ្វើឡើងដោយអ្នកតំណាងដោយអាណត្តិ (ច្បាប់ដើម ០១ច្បាប់ និងច្បាប់ចម្លងដែលបានធ្វើនីត្យានុកូលកម្ម ០២ច្បាប់) | 03 |
| 10 | ប័ណ្ណអចលនវត្ថុ (ច្បាប់ដើម) | 01 |
| 11 | ឯកសារពាក់ព័ន្ធផ្សេងទៀត ក្នុងករណីចាំបាច់ ÷ ....................................<br>(ច្បាប់ដើម ឬច្បាប់ចម្លងដែលបានធ្វើនីត្យានុកូលកម្ម) | 03 |